**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាអាជ្ញាកណ្តាល**

មជ្ឈមណ្ឌលភ្នំពេញ, អាគារ (A) , វិថី

សុធារស, សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន

ទូរស័ព្ទ/ទូរសារ : (៨៥៥-២៣)២២០ ៧៩៣

**លេខ និងឈ្មោះសំណុំរឿង : ៧៩/០៥ — អេវើរហ្គ្រីន អ៊ីភែរីល**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៦**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក : **យូ សួនទី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : **ទួន ស៊ីផាន់**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ : **កុយ នាម**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ : ក្រុមហ៊ុន អេវើរហ្គ្រីន អ៊ីភែរីល

អាសយដ្ឋាន : ផ្លូវសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ២៦៦ ៤៧៤ ទូរសារលេខ : ០២៣ ៨៨១ ៦២៨

**តំណាងភាគីនិយោជក :** ១-លោក ប៊ុត ឫទ្ធី ប្រធានរដ្ឋបាលក្រុមហ៊ុន

### ២- ភាគីកម្មករនិយោជិត

**ឈ្មោះ : សហជីពយុវជនខ្មែរក្រុមហ៊ុន អេវើរហ្គ្រីន អ៊ីភែរីល**

អាសយដ្ឋាន : ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១១ ៦២២ ៩៦៣ ទូរសារលេខ : គ្មាន

តំណាងកម្មករនិយោជិត :

១-លោក ម៉ៃ វឌ្ឍនា មន្ត្រីសហព័ន្ធសហជីពយុវជនខ្មែរ

២-លោក ហង់ សុរិយា មន្ត្រីសហព័ន្ធសហជីពយុវជនខ្មែរ

៣-លោក ឈុន ភារម្យ អនុប្រធានសហជីពយុវជនខ្មែរក្រុមហ៊ុន អេវើរហ្គ្រីន អ៊ីភែរីល

៤-លោក ងួន ចាន់ណា ប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន អេវើរហ្គ្រីន អ៊ីភែរីល

៥-លោក ស៊ិន ព្រីង ប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន អេវើរហ្គ្រីន អ៊ីភែរីល

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនសងប្រាក់ថ្លៃធ្វើសៀវភៅការងារ ករណីក្រុមហ៊ុននេះបានកាត់ប្រាក់ពីកម្មករលើសពីផ្លូវច្បាប់ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ០៩៩ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ០៩៩ និង ប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ៥១៣ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៥ (អាណត្តិទីបី) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី ១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយ របាយការណ៍ស្តីអំពីការមិនសះជា លេខ ៧៩៧ ក.ក.ប.វ/អក/វ.ក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៥ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៥ ។

## សវនាការ និង សង្ខេបនីតិវិធីមុនពេលធ្វើសវនាការ

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ “A” វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :**-ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៦ (វេលាម៉ោង០៨:០០ ដល់ម៉ោង១១:០០ នាទី )

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៥ មន្ត្រីវិវាទការងារប្រចាំខណ្ឌឫស្សីកែវ បានកោះអញ្ជើញភាគីទាំងពីរដើម្បីធ្វើការផ្សះផ្សាវិវាទរវាងភាគីកម្មករនិយោជិត និងក្រុមហ៊ុន អេវើរហ្គ្រីន អ៊ីភែរីល។ ភាគីកម្មករនិយោជិតទាមទារ

ឱ្យភាគីនិយោជកសងថ្លៃប្រាក់ធ្វើសៀវភៅការងារ ដែលក្រុមហ៊ុនបានកាត់ប្រាក់ពីកម្មករលើសពីការកំណត់តាមផ្លូវច្បាប់ ។ មន្ត្រីផ្សះផ្សាវិវាទបានព្យាយាមផ្សះផ្សាវិវាទនេះ ប៉ុន្តែភាគីទាំងពីរមិនបានឈានទៅរកដំណោះស្រាយបានឡើយ ។ ហេតុដូច្នេះ របាយការណ៍មិនសះជានេះ ក៏ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០០៥ ។ បន្ទាប់ពីទទួលបានសំណុំរឿងនេះ ភាគីទាំងពីរត្រូវបានក្រុមប្រឹក្សាអាជ្ញាកណ្តាលកោះអញ្ជើញឱ្យមកចូលរួមក្នុងសវនាការនៅថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៦ ។

ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមផ្សះផ្សាវិវាទនេះជាបន្តទៀត ប៉ុន្តែមិនទទួលបានការព្រមព្រៀងទេ ។ ដូច្នេះ ដំណើរការសវនាការក៏បានចាប់ផ្តើមនៅថ្ងៃទី ០៦ ខែមករា ឆ្នាំ ២០០៦ នៅម៉ោង៩ព្រឹក ដើម្បីស្វែងរកបន្ថែមនូវភស្តុតាង និងអង្គហេតុ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានបញ្ជាឱ្យភាគីវិវាទទាំងពីរផ្តល់នូវឯកសារនានា ដើម្បីគាំទ្រនូវការទាមទាររបស់ពួកគេ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានស្នើសុំឱ្យភាគីនិយោជក បង្ហាញវិក្ក័យប័ត្រនៃការបង់ប្រាក់ថ្លៃសៀវភៅការងារ ដែលនិយោជកបានអះអាងថា មន្ត្រីនៃក្រសួងការងារបានទារលើសកំណត់ច្បាប់ ឱ្យបានមុនថ្ងៃទី២៦ ខែមករា ឆ្នាំ ២០០៦ ប៉ុន្តែភាគីនិយោជមិនបានផ្តល់ឱ្យតាមការកំណត់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាលើចំណុចមិនសះជាទាំងអស់ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម :

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក : គ្មាន

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :

១- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពយុវជនខ្មែរក្រុមហ៊ុន អេវើរហ្គ្រីន អឹភែរីល ចុះបញ្ជិកាថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥

២- លិខិតលេខ ៧៧៣ ស.ស.យ.ខ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៥ របស់សហព័ន្ធសហជីពយុវជនខ្មែរ គោរពជូន ប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីសំណើសុំជួយដោះស្រាយនូវវិវាទការងារក្រុមហ៊ុន អេវើរហ្គ្រីន អឹបភែរីល ។

៣- លិខិតលេខ ៧៧២ ស.ស.យ.ខ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៥ របស់សហព័ន្ធសហជីពយុវជនខ្មែរ គោរពជូន នាយកក្រុមហ៊ុន អេវើរហ្គ្រីន អឹភែរីល ស្តីពីសំណើសុំជួបពិភាក្សា និង ដោះស្រាយនូវវិវាទការងារក្រុមហ៊ុន អេវើរហ្គ្រីន អឹភែរីល ។

៤- លិខិត ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៥ របស់កម្មករ កម្មការិនីនៃក្រុមហ៊ុន អេវើរប្រ៊ិន អ៊ីភែរីល គោរពជូន ប្រធានសហព័ន្ធសហជីពយុវជនខ្មែរ ស្តីពីសំណើសុំជួយធ្វើអន្តរាគមន៍ និង ដោះស្រាយនូវលក្ខខណ្ឌការងារមួយចំនួន ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- លិខិតលេខ ២០៣៣ ក.ក.ប.វ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៥ របស់ឯកឧត្តម **ញ៉ែប ប៊ុនជិន** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការសុំដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន អេវើរប្រ៊ិន អ៊ីភែរីល ។

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន អេវើរប្រ៊ិន អ៊ីភែរីល លេខ ៧៩៧ ក.ក.ប.វ /អក/វ.ក របស់លោក **កុយ ទេពដារ៉ាវុធ** ប្រធាននាយកដ្ឋានវិវាទការងារ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៥ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៥ ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ៤១៥ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៥

២- លិខិតអញ្ជើញភាគីនិយោជក ចូលរួមសវនាការ លេខ៤១៤ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៥

៣- កំណត់ហេតុស្តីពីការជ្រើសរើសអាជ្ញាកណ្តាលដោយការចាប់ឆ្នោត ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៥

៤- លិខិតលេខ ០១៣ លកអ. ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៦ របស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ជំរាបជូន ក្រុមហ៊ុន អេវើរប្រ៊ិន អ៊ីភែរីល ស្តីពីសំណើសុំឯកសារបន្ថែម។

## **អង្គហេតុ**

- ក្រោយពីបានពិនិត្យឯកសារផ្សេងៗដែលត្រូវបានដាក់ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល
- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- យោងតាមប្រកាសលេខ ០១៣ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៧ អាករជាផ្លូវការសម្រាប់ថ្លៃសៀវភៅការងារ គឺ ២.៥០០រៀល ( ប្រហែល០,៦២៥ដុល្លារ សហរដ្ឋអាមេរិក) ។

- ភាគីនិយោជកបានអះអាងថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ យកថ្លៃសៀវភៅការងារចំនួន ៣.០០ដុល្លារ សហរដ្ឋអាមេរិកក្នុងមួយនាក់ ។ ហេតុដូច្នេះ ភាគីនិយោជកបានបន្ថែមចំនួន០.៥០ដុល្លារ សហរដ្ឋអាមេរិកសម្រាប់បង្គ្រប់ថ្លៃសៀវភៅការងារឱ្យកម្មករនិយោជិតម្នាក់ៗ ។
- គោលបំណងរបស់ភាគីនិយោជកក្នុងការកាត់ប្រាក់ពីកម្មករនិយោជិតនេះ គឺ ដើម្បីជួយសម្រួលការងាររបស់កម្មករនិយោជិតក្នុងការទទួលបានសៀវភៅការងារនេះ ។ ភាគីនិយោជកផ្តល់ហេតុផលថា បន្ថែមលើអាករដែលកំណត់ជាផ្លូវការដោយសេចក្តីជូនដំណឹងលេខ ០១៣/៩៧ និងប្រកាសរួមលេខ ១៤២/០១ របស់ក្រសួងទទួលបន្ទុកវិស័យការងារ ប្រសិនបើកម្មករនិយោជិតចង់ធ្វើសៀវភៅការងារដោយខ្លួនគេផ្ទាល់ ពួកគេត្រូវចេញថ្លៃ និងពេលវេលាសម្រាប់ធ្វើដំណើរយ៉ាងតិច ក៏ពីរដងពីរោងចក្រទៅនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ចំណាយនេះ រួមមានសោហ៊ុយធ្វើដំណើរសំរាប់ទិញសំណុំបែបបទ និងឯកសារដាក់ពាក្យសុំ ដែលភ្ជាប់ជាមួយនូវលិខិតបញ្ជាក់ពីគ្រូពេទ្យ និងសំរាប់ទទួលយកសៀវភៅការងារពីនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ភាគីនិយោជកបានប៉ាន់ប្រមាណថា ចំណាយទាំងអស់នេះគឺមានចំនួនប្រហែលលើសពី៣.០០ដុល្លារសហរដ្ឋអាមេរិក ដោយមិនគិតពីការបាត់បង់ប្រាក់ខែប្រចាំថ្ងៃការងារ ដែលពួកគេត្រូវសុំឈប់ដើម្បីទៅធ្វើសៀវភៅការងារនោះផង ។ ប្រការនេះក៏ធ្វើឱ្យរំខានដល់ចង្វាក់ផលិតកម្មរបស់រោងចក្រផងដែរ ។ យោងតាមហេតុផលទាំងនេះ និងដើម្បីផលប្រយោជន៍របស់ភាគីទាំងសងខាង ចំនួនប្រាក់ដែលភាគីនិយោជកបានកាត់នោះ គឺសំរាប់តែបង់ឱ្យមន្ត្រីមកពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមករៀបចំឱ្យកម្មករនិយោជិតធ្វើសៀវភៅការងារជាក្រុមនៅក្នុងបរិវេណរោងចក្រតែប៉ុណ្ណោះ ។
- និយោជកបានបញ្ជាក់ថា គេបានប្រាប់ពីតម្លៃដែលមន្ត្រីក្រសួងការងារយកលើសពីតម្លៃតាមផ្លូវច្បាប់ដែរ តែកម្មករនិយោជិតមិនបានឆ្លើយតបមកវិញថា អនុញ្ញាត ឬមិនអនុញ្ញាតឱ្យបង់តាមតម្លៃដែលមន្ត្រីក្រសួងបានយកនោះទេ ។ ដោយរង់ចាំចម្លើយ ហើយមិនបានទទួលចម្លើយ និយោជកក៏សំរេចដោយឯកតោភាគីបង់ថ្លៃទៅតាមតម្លៃដែលមន្ត្រីក្រសួងការងារយក ។
- ភាគីនិយោជកបានជូនដំណឹងទៅកម្មករនិយោជិត តែមិនបានពិគ្រោះយោបល់ និងសុំសេចក្តីសំរេចពីកម្មករនិយោជិតក្នុងការកាត់ប្រាក់ចំនួន២.៥០ដុល្លារសហរដ្ឋអាមេរិក សំរាប់ចំណាយធ្វើសៀវភៅការងារឡើយ ។ ភាគីនិយោជកក៏សម្រេចជាឯកតោភាគីកាត់ប្រាក់ចំនួន ២.៥០ដុល្លារ សហរដ្ឋអាមេរិកពីកម្មករម្នាក់ៗនៅខែកក្កដា ឆ្នាំ២០០៥ ដើម្បីធ្វើសៀវភៅការងារឱ្យកម្មករនិយោជិត ។
- ភាគីនិយោជកបានរៀបចំជាដំណាក់កាលទី១ នៅខែ កញ្ញា ឆ្នាំ ២០០៥ និងដំណាក់កាលទី២ នៅខែ ធ្នូ ឆ្នាំ ២០០៥ ដើម្បីឱ្យកម្មករបានដាក់ពាក្យធ្វើសៀវភៅការងារ ។

## ហេតុផលនៃសេចក្ដីសំរេច

មាត្រា ៣២ នៃច្បាប់ស្ដីពីការងារតម្រូវឱ្យជនដែលមានសញ្ជាតិខ្មែរធ្វើការឱ្យនិយោជក ត្រូវតែមានសៀវភៅការងារ ។ មាត្រានេះក៏បានហាមឃាត់និយោជកមិនឱ្យប្រើប្រាស់កម្មករនិយោជិតណា ដែលមិនបានប្រតិបត្តិតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៣២ នេះ ។

យោងតាមអត្ថន័យនៃមាត្រានេះ ភាគីកម្មករនិយោជិតមានកាតព្វកិច្ចធ្វើសៀវភៅការងារដោយខ្លួនឯង ។ គ្មានបទប្បញ្ញត្តិណាមួយក្នុងនីតិការងារតម្រូវឱ្យភាគីនិយោជកធ្វើសៀវភៅការងារជំនួសឱ្យភាគីកម្មករនិយោជិតឡើយ ។ ប៉ុន្តែនិយោជកត្រូវបានតម្រូវដោយសេចក្ដីជូនដំណឹងលេខ ០១៣/៩៧ និង សេចក្ដីប្រកាសរួមលេខ ១៤៧/០១ ឱ្យសម្រួលដល់កម្មករនិយោជិតក្នុងការធ្វើសៀវភៅការងារ ។ គ្មានបទប្បញ្ញត្តិណាមួយ ដែលពន្យល់ច្បាស់លាស់អំពីអត្ថន័យនៃពាក្យ "សម្រួល" នេះទេ ។ ក្នុងការអនុវត្តជាក់ស្ដែង និយោជកខ្លះអនុញ្ញាតឱ្យកម្មករនិយោជិតឈប់សម្រាកពីការងារដើម្បីទៅធ្វើសៀវភៅការងារ រីឯនិយោជកខ្លះជួយរៀបចំឱ្យមន្ត្រីក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ មកធ្វើសៀវភៅនេះនៅក្នុងបរិវេណរោងចក្រ ដើម្បីឱ្យកម្មករនិយោជិតអាចទទួលបានសៀវភៅការងារ ។ ប្រការនេះជួយជំរុញដំណើរការធ្វើសៀវភៅការងារឱ្យបានកាន់តែឆាប់រហ័ស និងសន្សំសំចៃពេលវេលារបស់កម្មករនិយោជិត និងនិយោជក ។

យោងតាមមាត្រា ៣៦ នៃច្បាប់ស្ដីពីការងារ ដែលចែងថាការចេញសៀវភៅការងារត្រូវបង់ជូនថវិកាជាតិនូវអាករដែលមានអត្រា និងរបៀបទទួលប្រាក់ដូចមានកំណត់ក្នុងប្រកាសរួមនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងទទួលបន្ទុកវិស័យការងារ ។

យោងតាមសេចក្ដីជូនដំណឹងលេខ ០១៣/៩៧ និង សេចក្ដីប្រកាសរួមលេខ ១៤៧/០១ អាករសំរាប់ធ្វើសៀវភៅការងារគឺស្មើនឹង២៥០០រៀល ។ អាករនេះរួមមាន១៥០០រៀលសម្រាប់ថ្លៃឯកសារ និង១០០០រៀលសម្រាប់ថ្លៃតែម ។ នេះមានន័យថា ភាគីកម្មករនិយោជិតត្រូវបង់ថ្លៃសៀវភៅការងារដោយខ្លួនឯង ប្រសិនបើពួកគេធ្វើសៀវភៅការងារ ។

ប៉ុន្តែ គ្មានបទប្បញ្ញត្តិណាមួយដែលតម្រូវឱ្យជន ដែលត្រូវធ្វើសៀវភៅការងារត្រូវតែចំណាយលើសពីការកំណត់ដោយសេចក្ដីជូនដំណឹងលេខ ០១៣/៩៧ និងសេចក្ដីប្រកាសរួមលេខ ១៤៧/០១ ឡើយ ។ ហេតុដូច្នេះរាល់ការសម្រេចជាឯកតោភាគី ដែលតម្រូវឱ្យកម្មករនិយោជិតចេញថ្លៃធ្វើសៀវភៅការងារ ដែលលើសពីតម្លៃផ្លូវការកំណត់ដោយសេចក្ដីជូនដំណឹងលេខ ០១៣/៩៧ និង សេចក្ដីប្រកាសរួមលេខ ១៤៧/០១ មិនស្របនឹងបទប្បញ្ញត្តិនៃច្បាប់ការងារទេ ។ សូមមើលផងដែរនូវសេចក្ដីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល លេខ ២១/០៣-ឡូយាល់ខាំបូឌា លេខ ០៥/០៤-ថៃ ដូ និងលេខ ១០៦/០៤-ស៊ូត វ៉ៃ ។

ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានផ្ដល់ឱកាសជាច្រើនដងដល់ភាគីនិយោជក ដើម្បីឱ្យភាគីនិយោជកផ្ដល់នូវភស្តុតាងដែលខ្លួនអះអាងថា បានចំណាយប្រាក់លើសតម្លៃជាផ្លូវការសម្រាប់ការធ្វើសៀវភៅ

ការងារឱ្យកម្មករនិយោជិត ។ ប៉ុន្តែភាគីនិយោជកមិនបានផ្តល់ភស្តុតាងទាំងនេះតាមការស្នើសុំរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលតាមការកំណត់នៅត្រឹមថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៦ នោះទេ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា នៅក្នុងសំណុំរឿងមុនៗប្រសិនបើភាគីណាមួយ មិនបានផ្តល់នូវភស្តុតាង ដើម្បីគាំទ្រដល់ការអះអាងរបស់ខ្លួននៅក្នុងសវនាការទេ នាំឱ្យមានផលប៉ះពាល់ដល់ការពិចារណាលើវិវាទនេះ ។ សូមមើលសំណុំរឿងលេខ ១០/០៣-ហ្សាក់ស៊ីនតិច លេខ២៥/០៣-អេតវ៉ាន់ អ៊ិនដាស់ស្ទ្រៀល លេខ២២/០៤-វ៉ាហ្វល ឡឺរូយ៉ាល់ និង ៩១/០៤-ហានី វ៉ែរ ។

យោងតាមការបង្ហាញពីអង្គហេតុ អង្គច្បាប់ និង ហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសំរេច :

## បង្គាប់

បង្គាប់ឱ្យភាគីនិយោជកចេញសងកម្មករនិយោជិតនូវចំនួនទឹកប្រាក់ ដែលខ្លួនបានកាត់ប្រាក់លើសពីចំនួនផ្លូវការ ដែលបានកំណត់ក្នុងសេចក្តីជូនដំណឹងលេខ ០១៣/៩៧ និងសេចក្តីប្រកាសរួមលេខ ១៤៧/០១ សំរាប់ចំណាយធ្វើសៀវភៅការងារ ក្នុងរយៈពេល ៣សប្តាហ៍យ៉ាងយូរ ចាប់ពីពេលសេចក្តីបង្គាប់នេះចូលជាធរមាន។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់នេះមិនជាប់កាតព្វកិច្ចភ្ជាមទេ ។**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

## ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **យូ សួនឌី**

ហត្ថលេខា: -----------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **ទួន ស៊ីផាន់**

ហត្ថលេខា: -----------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **កុយ នាម**

ហត្ថលេខា: -----------------------------